មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៨-០១-២០០៦ -ព្រះរាជក្រម នស/រកម/០១០៦/០០១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ៧៦៦

២~ព្រះរាជក្រឹត្យ

២០-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០២១ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៣ រូប ជាឧបការីសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៧៧៧

២៧-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០៤២ ស្តីពីការតែងតាំងលោកស្រី **លឹម ឈីវហួរ** ជាឧកញ៉ា ៧៧៨

២៧-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០៤៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនា ភូមិមួយ ផលិតផលមួយ ហៅកាត់ថា "**គ១.ឥ១**" ៧៧៩

២៧-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០៤៤ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោសដល់ទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ៧៨១

២៧-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០៤៥ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោសដល់ទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ៨០១

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

០២-០២-២០០៦ -អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨០៦

០១-០២-២០០៦ -អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨០៨

០១-០២-២០០៦ -អនុក្រឹត្យលេខ ៨៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨១០

០១-០២-២០០៦ -អនុក្រឹត្យលេខ ៨៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨១១

០១-០២-២០០៦ -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៩

០១-០២-២០០៦ -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨២១

០២-០២-២០០៦ -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨២៣

០៣-០២-២០០៦ -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨២៥

III-**ការចារបណ្តាក្រសួង**

១-**ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

១៧-០១-២០០៦ -ប្រកាសលេខ ០២៨ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ុន ហ្វាង (ខេមបូឌា)ហ្គាមេន មេនូហ្វេកឈ័ររីង** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ស៊ុន ហ្វាង (ខេមបូឌា) ហ្គាមេន មេនូហ្វេកឈ័ររីង " ៨២៦

១៧-០១-២០០៦ -ប្រកាសលេខ ០២៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ជីម លី (ខេមបូឌា) ភីធីអ៊ី** បង្កើតរោងចក្រ "កាត់ដេរ ប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់" ដែលមានឈ្មោះថា " ជីម លី (ខេមបូឌា) ភីធីអ៊ី " ៨២៨

២៤-០១-២០០៦ -ប្រកាសលេខ ០៦១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ឌី.ធី.ឌី (ខេមបូឌា)ភីធីអ៊ី** បង្កើតរោងចក្រ "តម្លើងម៉ូតូ" ដែលមានឈ្មោះថា "ឌី.ធី.ឌី(ខេមបូឌា)" ៨៣០

២៤-០១-២០០៦ -ប្រកាសលេខ០៨៨ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **កំពត ស៊ីមេន ខូអិលធីឌី** បង្កើតរោងចក្រ "ផលិតស៊ីម៉ង់ត៍" ដែលមានឈ្មោះថា " កំពត ស៊ីមេន ខូអិលធីឌី " ៨៣២

២៤-០១-២០០៦ -ប្រកាសលេខ ០៨៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **តាក់ សាន់ (ខេមបូឌា) ឡោនទ្រី** បង្កើតរោងចក្រ "បោកគក់សម្លៀកបំពាក់" ដែលមានឈ្មោះថា " តាក់ សាន់ (ខេមបូឌា) ឡោនទ្រី " ៨៣៤

២-**ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

០៩-១២-២០០៥ -លិខិតលេខ ២៧៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី ជេ អេស ខមភេនី** ៨៣៦

២១-១២-២០០៥ -លិខិតលេខ ២៨១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេមបូឌាន អ៊ែរ ស៊ីវីស** ៨៣៨

២១-១២-២០០៥ -លិខិតលេខ ២៨១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេស អ ម៉ាយ អិន ខនស្ត្រាក់សិន អ៊ីម & អិច** ៨៤០

២១-១២-២០០៥ -លិខិតលេខ ២៨១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **(ខេមបូឌា) អូវើស៊ី នាយណា អ៊ិនវេសមេន ខូ អិលធីឌី** ៨៤២

២២-១២-២០០៥ -លិខិតលេខ ២៨២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **(ខេមបូឌា) យ៉ុង ឡុង អ៊ិនធើណេសិនណល គ្រុប** ៨៤៤

២២-១២-២០០៥ -លិខិតលេខ ២៨២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គោលម៉ាក ឌីវេឡុបមេន លីមីធីត** ៨៤៦

២២-១២-២០០៥ -លិខិតលេខ ២៨៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌី មាន** ៨៤៧

២៣-១២-២០០៥ -លិខិតលេខ ២៨៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អឹត អេវើ ហ្គ្រីន (ខេមបូឌា)** ៨៤៩

២៣-១២-២០០៥ -លិខិតលេខ ២៨៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឡឺ ដូម៉ែន ខូ អិលធីឌី** ៨៥១

២៣-១២-២០០៥ -លិខិតលេខ ២៨៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធនាគារ ហំរ ជីង ភីអិលស៊ី** ៨៥២

២៦-១២-២០០៥ -លិខិតលេខ ២៨៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អង្គរ អភិវឌ្ឍន៍ ខូ អិលធីឌី** ៨៥៤

២៦-១២-២០០៥ -លិខិតលេខ ២៨៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ថៃរ៉ុង (ខេមបូឌា) នីតធីង** ៨៥៦

ព្រះរាជក្រម

នស/រកម/០១០៦/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

ការទូទាត់ថវិកាទូទៅរបស់រដ្ឋ

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.–

ត្រូវបានយល់ព្រមតាមការអនុវត្តន៍នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ :

ឯកតា: លានរៀល

កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣	ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៣	ការអនុវត្តន៍ថវិកាឆ្នាំ ២០០៣
សរុបចំណូល = (I.១ + II.១)	២.៨៣០.០០០	២.៧៤១.១៣០
សរុបចំណាយ = (I. ២ +II.២)	២.៨៣០.០០០	៣.០៤៤.៧៤០
ចំនួននិទ្ទភាពនៃគណនេយ្យចំណូល/ចំណាយ	—	(-)៣០៣.៦១០
I. កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ		
I.១ ចំណូលថវិកា	២.១៣០.០០០	១.៩០៣.៦៣៨
• ចំណូលចរន្ត	១.៩៨០.០០០	១.៧៣៣.២៣២
• ចំណូលជាមូលធនក្នុងប្រទេស	២៥.០០០	៣១.៣៧៥
• ចំណូលជាមូលធនក្រៅប្រទេស	១២៥.០០០	១៣៩.០៣១
I.២ ចំណាយថវិកា	២.១៣០.០០០	២.២០៧.២៤៨
• ចំណាយចរន្ត	១.៧៦៥.០០០	១.៧៥៨.១៤៤
• ចំណាយជាមូលធន	៣៦៥.០០០	៤៤៩.១០៤
II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ[១]		
II.១ ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៧០០.០០០	៨៣៧.៤៩២
II.២ចំណាយជាមូលធនដោយធនធានសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៧០០.០០០	៨៣៧.៤៩២

[១] គំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានលើកឡើងនេះ គ្រាន់តែជាការចង្អុលបង្ហាញបណ្ដោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់តាមរតនាគារជាតិនិងមិនបានចុះកិច្ចបញ្ជីការគណនេយ្យនៅក្នុងលេខាធិការរតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះ គឺជាលទ្ធផលដែលសំរេចបានដោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្ដល់មូលនិធិ ។

មាត្រា ២.-

ចំណូលថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកាថវិកា នៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៣ ត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៣ និងដែលបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

លទ្ធផលដែលសំរេចបានស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេស ផ្ទាល់ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៣ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា ដូចមាននៅក្នុងភាគទី II នៃតារាង "ក" និង ចំពោះចំណាយត្រូវបានលំអិតនៅក្នុងតារាង "ខ២" ដូចមានជូនភ្ជាប់មកជាមួយច្បាប់នេះ ។

ជំពូកទី ២

បទប្បញ្ញត្តិ

ស្តីពីកិច្ចប្រតិបត្តិការចំណូលចំណាយថវិកា

ដែលបានអនុវត្តដោយរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

មាត្រា ៣.-

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទានអាករផលិតផល និងផលចុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិបរិភាគ និងធនធានដែលបានមកពីការខ្ចី ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់សរុប.................២.១៣០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់...........១.៩០៣.៦៣៨ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន..................(-)២២៦.៣៦២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ :

ចំណូលចរន្ត:

-គំរោង................១.៩៨០.០០០ លានរៀល

-ការសំរេចបាន......១.៧៣៣.២៣២ លានរៀល

-មានចំនួនខ្វះ........(-)២៤៦.៧៦៨ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស :

-គំរោង..................២៥.០០០ លានរៀល

-ការសំរេចបាន...........៣១.៣៧៥ លានរៀល

-មានចំនួនលើស........(+)៦.៣៧៥ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស :

-គំរោង..................១២៥.០០០ លានរៀល

-ការសំរេចបាន.........១៣៩.០៣១ លានរៀល

-មានចំនួនលើស......(+)១៤.០៣១ លានរៀល

មាត្រា ៤.-

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់សរុប............២.១៣០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់............២.២០៧.២៤៨ លានរៀល

ដូច្នេះមានចំណាយលើសឥណទានថវិកាចំនួន....(+)៧៧.២៤៨ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ :

ចំណាយចរន្ត :

-គំរោង..............១.៧៦៥.០០០ លានរៀល

-ការសំរេចបាន......១.៧៥៨.១៤៤ លានរៀល

-មានចំនួនខ្វះ...........(-)៦.៨៥៦ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-គំរោង................៣៤០.០០០ លានរៀល

-ការសំរេចបាន........៣៣៣.១៩០ លានរៀល

-មានចំនួនខ្វះ............(-)៦.៨១០ លានរៀល

ចំណាយជាមូលធននៃការវិលល់បំណុល :

-គំរោង..................២៥.០០០ លានរៀល

-ការសំរេចបាន..........១១៥.៩១៥ លានរៀល

-មានចំនួនលើស.......(+)៩០.៩១៥ លានរៀល

មាត្រា ៥.-

ការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលបានសំរេចដោយរតនាគារជាតិ ដូចមានចែងនៅក្នុងមាត្រា ៣ និងមាត្រា ៤ នៃច្បាប់នេះបានបង្ហាញជាលទ្ធផលនូវឱនភាពគណនេយ្យនៃចំណូល និងចំណាយដូចតទៅ :

-ចំណូលថវិកា ដែលបានសំរេចដោយរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួន................................ ១.៩០៣.៦៣៨ លានរៀល

-ចំណាយថវិកា ដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួន..................................២.២០៧.២៤៨ លានរៀល

-ឱនភាពគណនេយ្យពិតនៃចំណូលនិងចំណាយ..(-)៣០៣.៦១០ លានរៀល

ឱនភាពគណនេយ្យនេះ គឺជាលទ្ធផលនៃ :

-ឱនភាពនៃចំណូលចរន្ត និង ចំណាយចរន្ត....(-)២៤.៩១២ លានរៀល

-និង ឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន...(-)២៧៨.៦៩៨ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ឱនភាពគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់ (-)៣០៣.៦១០ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលដែលបានបើកនៅក្នុងលេខានៃរតនាគារជាតិ ។

ជំពូកទី ៣
បទប្បញ្ញត្តិ
ស្តីពីវិនិយោគសាធារណៈ
ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់
ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

មាត្រា ៦.–

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ និង ដែលបានគ្រោងទុក សរុបចំណូលស្មើនឹងសរុបចំណាយ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់.....................៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.............៨៣៧.៤៩២ លានរៀល

ដូច្នេះមានចំនួនលើស.....................(+)១៣៧.៤៩២ លានរៀល

ជំពូកទី ៤
បទប្បញ្ញត្តិស្តីពី
តុល្យភាពហិរញ្ញវត្ថុសាធារណៈ
សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

មាត្រា ៧.–

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថានភាពនៃថវិកាទូទៅរបស់រដ្ឋ បានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការដូចតទៅ :

-កិច្ចប្រតិបត្តិការថវិកាតារាង "ក" ចំណូលថវិកាទូទៅរបស់រដ្ឋ និង តារាង "ខ" ចំណាយថវិកាទូទៅរបស់រដ្ឋ ។

-កិច្ចប្រតិបត្តិការនៃរតនាគារជាតិ ។

-ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋ ជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចខាងក្រោម :

ឯកតា: លានរៀល

តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ	ចំនួនទឹកប្រាក់	ចំនួនលើស(+)/ ឱនភាព(-)
I- ចំណូលក្នុងប្រទេស	១.៧៦៤.៦០៧	
I- ១ ចំណូលចរន្ត	១.៧៣៣.២៣២	
I- ២ ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម)	៣១.៣៧៥	
II- ចំណាយថវិកា	២.៩២៨.៨២៥	
II-១ ចំណាយចរន្ត	១.៧៥៨.១៤៤	
II-២ ចំណាយជាមូលធន[២]	១.១៧០.៦៨២	
ក្នុងនោះ ÷		
+ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស	៣៣៣.១៩០	
-ដោយមូលនិធិថវិកា	២៦៦.៩៣៣	
• គំរោងវិនិយោគ (សាងសង់,ទិញសម្ភារៈ)	១៩៨.១៣៧	
• បរិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៦៨.៧៩៦	
-ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្ដល់ជំនួយ	៦៦.២៥៧	
+ វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ)	៨៣៧.៤៩២	
ក. ឱនភាពថវិកាចរន្ត (តាមនិយមន័យសន្យាផ្ដល់) (I.១ - II.១.)		(-) ២៤.៩១២
ខ. ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្យាផ្ដល់) (I. - II.)		(-)១.១៦៤.២១៨
III កំណែតម្រូវ		(+)១៧២.២០៥[៣]
អតិរេកនៃថវិកាចរន្ត (តាមនិយមន័យបេឡា) = (III. + ក.)		(+)១៤៧.២៩៣
ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) = (III. + ខ.)		(-) ៩៩២.០១៣
IV- ហិរញ្ញប្បទាននៃឱនភាព		(+)៩៩២.០១៣
១-ហិរញ្ញប្បទានក្រៅប្រទេស		(+) ៨៨៦.០៩១
• ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្ដល់ជំនួយ		(+)១៣៩.០៣១
• ជំនួយគំរោងការ		(+)៨០៦.៣៤០[៤]
• ការរំលស់បំណុលបរទេស		(-) ៥៩.២៨០
២-ហិរញ្ញប្បទានក្នុងប្រទេស		(+)១០០.៤៤៨
• ហិរញ្ញប្បទានធនាគារ		(-)៥.៣០២
ក្នុងនោះ - ខ្ចីពីធនាគារ		—
- ការរំលស់បំណុលក្នុងប្រទេស		(-)១.៨៨៣
• ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ		(+)៥១.៩៧៥
• វិស័យឯកជន		(+) ៥១.៧៦៣
• លំអៀងគណនីរវាងធនាគារជាតិនិងហិរញ្ញវត្ថុ		(+)២.០១២
៣- កិច្ចប្រតិបត្តិការកំពុងដំណើរការ		(+)៥.៤៧៤

[២] មិនបានគិតការរំលស់បំណុល ១១៥.៩១៥ លានរៀល ។ [៣] បរិបំរួលសុទ្ធនៃអាណត្តិបើកប្រាក់ ដែលមានសល់មិនទាន់បាន បើកផ្ដល់ទៅធនាគារ និងបុរេប្រទាន ត្រូវធ្វើនិយ័តភាវូបនីយកម្ម ។ [៤] ទៅមិនទាន់គិតចូលចំនួន ៣១.១៥២ លានរៀល ដែលបានចំណាយហើយ ។

ជំពូកទី ៥

បទប្បញ្ញត្តិស្តីពីការទូទាត់ថវិកា
របស់ខេត្ត ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

មាត្រា ៨.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និង មាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវបានយល់ព្រមតាមការអនុវត្តន៍នូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលលេចចេញជាលទ្ធផលដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ :

ឯកតា: រៀល

កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៣	ការអនុវត្តន៍ថវិកា ខេត្ត ក្រុងឆ្នាំ ២០០៣	លើស(+) ខ្វះ (-)
សរុបចំណូល	៨៩.០០០.០០០.០០០	៨៥.៧៧០.៨៧៧.១២៥	-៣.២២៩.១២២.៨៧៥
សរុបចំណាយ	៨៩.០០០.០០០.០០០	៨៥.៣៩២.៩៥៦.១០៩	-៣.៦០៧.០៤៣.៨៩១
អតិរេកគណនេយ្យនៃចំណូល និង ចំណាយ		៣៧៧.៩២១.០១៦	+៣៧៧.៩២១.០១៦
កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង			
I. ចំណូលថវិកា	៨៩.០០០.០០០.០០០	៨៥.៧៧០.៨៧៧.១២៥	-៣.២២៩.១២២.៨៧៥
-ចំណូលចរន្ត	៨៩.០០០.០០០.០០០	៨៥.៧៧០.៨៧៧.១២៥	-៣.២២៩.១២២.៨៧៥
• ចំណូលសារពើពន្ធ	៤១.៧០០.០០០.០០០	៣៨.៨២២.១៦០.៧១៨	-២.៨៧៧.៨៣៩.២៨២
• ចំណូលពុំមែនសារពើពន្ធ	១០.៣០០.០០០.០០០	៩.៩៤៨.៧១៦.៤០៧	-៣៥១.២៨៣.៥៩៣
• ឧបត្ថម្ភពីថវិការដ្ឋ	៣៧.០០០.០០០.០០០	៣៧.០០០.០០០.០០	០
-ចំណូលជាមូលធន	០	០	
• ចំណូលជាមូលធនផ្ទៃក្នុង	០	០	
• ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ (កម្មវិធីសីលា)	០	០	០
II. ចំណាយថវិកា	៨៩.០០០.០០០.០០០	៨៥.៣៩២.៩៥៦.១០៩	-៣.៦០៧.០៤៣.៨៩១
-ចំណាយចរន្ត	៨៩.០០០.០០០.០០០	៨៥.៣៩២.៩៥៦.១០៩	-៣.៦០៧.០៤៣.៨៩១
-ចំណាយជាមូលធន	០	០	០
III. អតិរេកថវិកា	០	៣៧៧.៩២១.០១៦	+៣៧៧.៩២១.០១៦

មាត្រា ៩.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ៣៧៧.៩២១.០១៦ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

ជំពូកទី ៦

បទប្បញ្ញត្តិស្តីពី

និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ

ចំណាយថវិកាបន្ថែមសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

មាត្រា ១០.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងបទប្បញ្ញត្តិនានានៃវិសោធនកម្មច្បាប់នេះ និងមាត្រា ៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៤/០០៥ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ត្រូវបានអនុម័តយល់ព្រមឱ្យចំណាយថវិកាបន្ថែមលើថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដូចខាងក្រោម :

-ចំណាយសំរាប់រៀបចំកិច្ចប្រជុំអភិបាលក្រុងប្រើភាសាបារាំងចំនួន ២.២០០ លានរៀល

-ចំណាយក្នុងក្របខ័ណ្ឌនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣ ចំនួន ១៣.១៦៥ លានរៀល ។

-ចំណាយសំរាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានឆ្នាំ ២០០៣ ចំនួន ៧.៨៨៥ លានរៀល

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ១១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

ពាល.០១០៦.០១៩ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឆាខី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០៧១

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

១- ឯកឧត្ដម **ច័ន្ទ តារា** ជាឧបការីសម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- ឯកឧត្ដម **សុខ គួចហាំ** ជាឧបការីសម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

៣- ឯកឧត្ដម **ជា សំណាង** ជាឧបការីសម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០២០១-០២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦

លេខៈ ៦៥ ច.ល

ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកុម្ភៈឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោកស្រី លីម ឈីវហ្វូរ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ពរល.០៦០១.០៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦

លេខៈ ២១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បង្កើតគណៈកម្មាធិការជាតិជំរុញចលនា " **ភូមិមួយ ផលិតផលមួយ** " ហៅកាត់ថា "**ភ១.ផ១**" ដែលមានសមាសភាពដូចខាងក្រោម :

១- សម្តេច **ហ៊ុន សែន** ប្រធាន

២- ឯកឧត្តម **សុខ អាន** អនុប្រធាន

៣- ឯកឧត្តម **សុន គន្ធរ** អគ្គលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២ : តួនាទី ភារកិច្ចនៃ "គ១.៨១" សមាសភាពសមាជិក ដែលជាតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអគ្គលេខាធិការរង មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន រួមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន "គ១.៨១" នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស-០២០១-០៤៩

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦

លេខ: ៥៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ធាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ៣៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **ហ៊ុយ ចយ** ភេទប្រុស អាយុ៤១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-០២-១៩៩៣ ពីបទសម្លាប់មនុស្សដោយចេតនាគិតទុកជាមុន និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៦ ចុះថ្ងៃទី ០៧-១២-១៩៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

២-ទណ្ឌិតឈ្មោះ **ខៀវ យ៉ាវយុទ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៩-១៩៩៣ ពីបទប្លន់ទ្រព្យសម្បត្តិ និងសម្លាប់មនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១២-៨-១៩៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៣-ទណ្ឌិតឈ្មោះ **សូ ស្រៀន** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៨-១៩៩២ ពីបទបាញ់សម្លាប់មនុស្សដោយគ្រោងទុកជាមុន និងប្លន់ទ្រព្យសម្បត្តិប្រជាជនដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ១៧-៣-១៩៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤-ទណ្ឌិតឈ្មោះ **ជឿម ចក់** ភេទប្រុស អាយុ ៩៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-១៩៩៨ ពីបទសមគំនិតសម្លាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិប្រជាជន ក្រុមប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ២៦-១០-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៥-ទណ្ឌិតឈ្មោះ **សុខ នៅ** ភេទប្រុស អាយុ ៩២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៦-១៩៩៨ ពីបទសមគំនិតសម្លាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិប្រជាជន ក្រុមប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ២៦-១០-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៦-ទណ្ឌិតឈ្មោះ **គិន ម៉ុនថា** ភេទប្រុស អាយុ ៤៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-១៩៩៨ ពីបទសមគំនិតសម្លាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិប្រជាជន ក្រុមប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ២៦-១០-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៧-ទណ្ឌិតឈ្មោះ **ទ័ន យឿន** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-១១-១៩៩៧ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ និងសម្លាប់មនុស្សដោយចេតនាហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ០២-៣-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៨-ទណ្ឌិតឈ្មោះ **ហាម ចឿប** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-០១-១៩៩៧ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាល ក្រមលេខ ២២ ចុះថ្ងៃទី ២០-៣-១៩៩៧ របស់តុលាការខេត្តសៀមរាប ។

៩-ទណ្ឌិតឈ្មោះ **សឿន កូយ** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-០១-១៩៩៧ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាម អំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ២០-៣-១៩៩៧ របស់តុលាការខេត្តសៀមរាប ។

១០-ទណ្ឌិតឈ្មោះ **អ៊ុំ អាន** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៤-១៩៩៦ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ៨៣ ចុះថ្ងៃទី ០៩-៨-១៩៩៦ របស់តុលាការខេត្តសៀមរាប ។

១១-ទណ្ឌិតឈ្មោះ **មាស ស៊ុយ៉ាន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៣-១៩៩៦ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ ចុះថ្ងៃទី ០២-៧-១៩៩៦ របស់តុលាការខេត្តសៀមរាប ។

១២-ទណ្ឌិតឈ្មោះ **សុត ផាត** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១០-១៩៩៨ ពីបទឃាដកម្មគិតទុកជាមុន និងការកាន់កាប់អាវុធខុសពីបទបញ្ជា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ១២-០២-១៩៩៩ របស់តុលាការខេត្តសៀមរាប ។

១៣-ទណ្ឌិតឈ្មោះ **អ៊ំ ប៊្រុចអាន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-១៩៩៥ ពីបទមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១-១២-១៩៩៥ របស់តុលាការខេត្តក្រចេះ ។

១៤-ទណ្ឌិតឈ្មោះ **អ៊ំ ប៊្រុចឆាន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-១៩៩៥ ពីបទមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១-១២-១៩៩៥ របស់តុលាការខេត្តក្រចេះ ។

១៥-ទណ្ឌិតឈ្មោះ **ហេង ឌុល** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៥-១៩៩០ ពីបទធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុន និងប្លន់ទ្រព្យសម្បត្តិ មានបក្សពួក មានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៤-០៧-១៩៩១ របស់តុលាការខេត្តកំពង់ចាម ។

១៦-ទណ្ឌិតឈ្មោះ **ឡុង រ៉ៃ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៤-១៩៨៧ ពីបទធ្វើមនុស្សឃាតដោយចេតនាលើប្រពន្ធនិងកូន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតាមអំណោចសាលក្រមលេខ ១០ ចុះថ្ងៃទី ០៧-១២-១៩៨៧ របស់តុលាការខេត្តកំពង់ចាម ។

១៧-ទណ្ឌិតឈ្មោះ **សេក សេខ** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៥-១៩៩០ ពីបទធ្វើមនុស្សឃាតគិតទុកជាមុន និងប្លន់ទ្រព្យសម្បត្តិ មានបក្សពួក មានអាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតាមអំណោចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៤-០១ ១៩៩១ របស់តុលាការខេត្តកំពង់ចាម ។

១៨-ទណ្ឌិតឈ្មោះ **ហាក់ ហំ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-០១-១៩៩១ ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតាមអំណោចសាលក្រមលេខ ២០ ចុះថ្ងៃទី ២៥-៧-១៩៩១ របស់តុលាការខេត្តកំពង់ចាម ។

១៩-ទណ្ឌិតឈ្មោះ **គង់ សេត** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-១៩៩១ ពីបទធ្វើមនុស្សឃាតមិនបានសម្រេចចាប់បង្ខំសេពសន្ថវៈ និងប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណោចសាលក្រមលេខ ៣៥ ចុះថ្ងៃទី ១៦-១២-១៩៩១ របស់តុលាការខេត្តកំពង់ចាម ។

២០-ទណ្ឌិតឈ្មោះ **ហេខ គី** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៣-១៩៩២ ពីបទធ្វើមនុស្សឃាតដោយចេតនា និងប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៧ ចុះថ្ងៃទី ២១-៥-១៩៩២ របស់តុលាការខេត្តកំពង់ចាម ។

២១-ទណ្ឌិតឈ្មោះ **ខឹន ញ៉ៅ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-០១-១៩៩០ ពីបទធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុននិងមានអាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណោចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៤-៥-១៩៩១ របស់តុលាការខេត្តកំពង់ចាម ។

២២-ទណ្ឌិតឈ្មោះ **ស្រ៊ុន អូន** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៦-១៩៩១ ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណោចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ១៦-១២-១៩៩១ របស់តុលាការខេត្តកំពង់ចាម ។

២៣-ទណ្ឌិតឈ្មោះ **យ៉ន់ យ៉ុន** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-៨-១៩៩២ ពីបទធ្វើមនុស្សឃាតដោយចេតនា មានបក្សពួក មានអាវុធ និងប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជន

ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ១៨-១១-១៩៩២ របស់តុលាការខេត្តកំពង់ចាម ។

២៤-ទណ្ឌិតឈ្មោះ **អ៊ឹម តុក្កា** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៣-១៩៩២ ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជាជន មានបក្សពួក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ២១-៥-១៩៩២ របស់តុលាការខេត្តកំពង់ចាម ។

២៥-ទណ្ឌិតឈ្មោះ **គង់ ថា** ហៅ **មឿន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៧-១៩៩៥ ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន និងប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ២៣-៥-១៩៩៦ របស់តុលាការខេត្តកំពត ។

២៦-ទណ្ឌិតឈ្មោះ **គង់ អឿម** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៥-១៩៩៦ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ២១-១០-១៩៩៦ របស់តុលាការខេត្តកំពត ។

២៧-ទណ្ឌិតឈ្មោះ **មាស សុខេន** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១០-១៩៩៤ ពីបទធ្វើមនុស្សឃាតគិតទុកជាមុន និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០១"គ" ចុះថ្ងៃទី ២៥-០១-១៩៩៥ របស់តុលាការក្រុងភ្នំពេញ ។

២៨-ទណ្ឌិតឈ្មោះ **គង់ ចាន់នី** ភេទ ស្រី អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-១១-១៩៩២ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៤ ចុះថ្ងៃទី ១០-៥-១៩៩៤ របស់តុលាការខេត្តកណ្តាល ។

២៩-ទណ្ឌិតឈ្មោះ **នុខ ថុល** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៦-១៩៩៥ ពីបទធ្វើមនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨"ព" ចុះថ្ងៃទី ១៤-១១-១៩៩៥ របស់តុលាការខេត្តកណ្តាល ។

៣០-ទណ្ឌិតឈ្មោះ **ជា តឿ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៨-១៩៩៤ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤"ក" ចុះថ្ងៃទី ២០-០២-១៩៩៥ របស់តុលាការខេត្តកណ្តាល ។

៣១-ទណ្ឌិតឈ្មោះ **នី នឿ** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-១២-១៩៩៤ ពីបទមនុស្សឃាតដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណោចសាលក្រមលេខ ០៧"ក" ចុះថ្ងៃទី ០៣-០២-១៩៩៥ របស់តុលាការខេត្តកណ្តាល ។

៣២-ទណ្ឌិតឈ្មោះ **ពៅ អ៊ន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៨-១៩៩៤ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណោចសាលក្រមលេខ ២៦៨ ចុះថ្ងៃទី ០១-១២-១៩៩៤ របស់តុលាការខេត្តកណ្តាល ។

៣៣- ទណ្ឌិតឈ្មោះ **ឌុយ ឈឿន** ភេទ ប្រុស អាយុ ៤០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៩-១៩៩៣ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន មានបក្សពួក មានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៨-០២-១៩៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៣៤- ទណ្ឌិតឈ្មោះ **ផាំ ផយ** ភេទ ប្រុស អាយុ ៤៣ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៩-១៩៩៣ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុនមានបក្សពួកមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៨-០២-១៩៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៣៥- ទណ្ឌិតឈ្មោះ **ជាំ គងណាយ** ភេទ ប្រុស អាយុ ៣៤ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១០-១៩៩៣ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន មានបក្សពួក មានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៨-០២-១៩៩៥ របស់ តុលាការខេត្តបន្ទាយមានជ័យ ។

៣៦- ទណ្ឌិតឈ្មោះ **ឌួច នី** ភេទ ប្រុស អាយុ ៣៧ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០១-១៩៩៤ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ១២៥ ចុះថ្ងៃទី ២៣-៥-១៩៩៤ របស់តុលាការខេត្តកណ្តាល ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ៣២ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **ទិន សុជាតិ** ហៅ **តី** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅ ថ្ងៃទី ១៤-៧-១៩៩៧ ពីបទប្លន់ និងសម្លាប់មនុស្សគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណោចសាលក្រមលេខ ៦៣ ចុះថ្ងៃទី ០៩-៩-១៩៩៧ របស់តុលាការខេត្តកំពង់ឆ្នាំង ។

២-ទណ្ឌិតឈ្មោះ **សៀង មានន្ទ** ហៅ **អៀង ស៊ីធន់** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៣-១៩៩៥ ពីបទបាញ់សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១១-៩-១៩៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៣-ទណ្ឌិតឈ្មោះ **សាន់ ពិសិដ្ឋ** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៥-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៤ ចុះថ្ងៃទី ១០-១០-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤-ទណ្ឌិតឈ្មោះ **សុះ សំអែ** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-០១-១៩៩៩ បទបាញ់សម្លាប់មនុស្សដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី ០៦-៧-១៩៩៩ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៥-ទណ្ឌិតឈ្មោះ **វ៉ាយ ឈន** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៨-២០០០ ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥ ចុះថ្ងៃទី ១១-១០-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៦-ទណ្ឌិតឈ្មោះ **ម៉ាន ម៉ាត់** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៤-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៤ ចុះថ្ងៃទី ១២-៩-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៧-ទណ្ឌិតឈ្មោះ **អ៊ឹ ចុន** ភេទស្រី អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-០២-២០០១ ពីបទប្លន់ និងមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាម អំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ២០-៦-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៨-ទណ្ឌិតឈ្មោះ **ឌន ទី** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៩-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធដែលច្បាប់ហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តសៀមរាប ។

៩-ទណ្ឌិតឈ្មោះ **ញ៉ាន យឿត** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៩-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធដែលច្បាប់ហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទា

ទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តសៀមរាប ។

១០-ទណ្ឌិតឈ្មោះ **ឈុន ម៉ន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៧-១៩៩៩ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ ចុះថ្ងៃទី ២០-១០-១៩៩៩ របស់តុលាការខេត្តសៀមរាប ។

១១-ទណ្ឌិតឈ្មោះ **ឈាន យ៉ុន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤ ៧-១៩៩៩ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ ចុះថ្ងៃទី ២០-១០-១៩៩៩ របស់តុលាការខេត្តសៀមរាប ។

១២-ទណ្ឌិតឈ្មោះ **មាគ នោ** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៣-២០០០ ពីបទសមគំនិតអំពើមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២០ ចុះថ្ងៃទី ០៤-១០-២០០០ របស់តុលាការ ខេត្តសៀមរាប ។

១៣-ទណ្ឌិតឈ្មោះ **ឡុម សោត** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៣-២០០០ ពីបទសមគំនិតអំពើមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២០ ចុះថ្ងៃទី ០៤-១០-២០០០ របស់តុលាការខេត្តសៀមរាប ។

១៤-ទណ្ឌិតឈ្មោះ **ខិន សុះ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០១-១៩៩៧ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២១-៣-១៩៩៧ របស់តុលាការខេត្តសៀមរាប ។

១៥-ទណ្ឌិតឈ្មោះ **ថាវ ថន** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៦-១៩៩៨ ពីបទប្លន់ និងការកាន់កាប់អាវុធដែលហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៨ ចុះថ្ងៃទី ២៥-៩-១៩៩៨ របស់តុលាការខេត្តសៀមរាប ។

១៦-ទណ្ឌិតឈ្មោះ **ម៉ុក លី** ភេទប្រុស អាយុ ១៨ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៩-២០០០ ពីបទមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៧ ចុះថ្ងៃទី ០២-១១-២០០០ របស់តុលាការខេត្តក្រចេះ ។

១៧-ទណ្ឌិតឈ្មោះ **ផេង សុខលី** ភេទប្រុស អាយុ ៣១ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-១២-១៩៩៩ ពីបទប្លន់ចាប់ជីវិត និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១១-៤-២០០០ របស់តុលាការខេត្តក្រចេះ ។

១៨-ទណ្ឌិតឈ្មោះ **ចិន ម៉ៅ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៩-១៩៩៩ ពីបទប៉ុនប៉ងសម្លាប់ និងប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណោចសាលក្រមលេខ ៩៧ ចុះថ្ងៃទី ០៨-១១-១៩៩៩ របស់តុលាការខេត្តក្រចេះ ។

១៩-ទណ្ឌិតឈ្មោះ **ច្រាក់ សិដ្ឋ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៧-២០០០ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណោចសាលក្រមលេខ ៧០ ចុះថ្ងៃទី ១៦-៧-១៩៩៨ របស់តុលាការខេត្តក្រចេះ ។

២០-ទណ្ឌិតឈ្មោះ **យឹម សោភ័ណ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៣-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណោចសាលក្រមលេខ ៨២"ក" ចុះថ្ងៃទី ១៤-៦-២០០១ របស់តុលាការខេត្តកំពង់ចាម ។

២១-ទណ្ឌិតឈ្មោះ **អ៊ុក ខន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-១១-១៩៩៩ ពីបទភេរវកម្ម ចាប់ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណោចសាលដីកាលេខ ៥២"ក" ចុះថ្ងៃទី ២៩-១២-២០០៤ របស់សាលាឧទ្ធរណ៍ ។

២២-ទណ្ឌិតឈ្មោះ **ម៉ុំ ពិសិដ្ឋ** ភេទប្រុស អាយុ ២៣ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៣-៩៨ ពីបទចាប់មនុស្សជំរិតយកប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណោចសាលដីកា លេខ ៦៧"ខ" ចុះថ្ងៃទី ១៦-១១-២០០៤ របស់សាលាឧទ្ធរណ៍ ។

២៣-ទណ្ឌិតឈ្មោះ **អ៊ុន ចន្ធា** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-៧-១៩៩៥ ពីបទសម្លាប់មនុស្សដោយចេតនាគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណោចសាលក្រមលេខ ២១ ចុះថ្ងៃទី ០៦-៦-១៩៩៦ របស់តុលាការខេត្តកំពត ។

២៤-ទណ្ឌិតឈ្មោះ **គីម សេង** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៧-១៩៩៦ ពីបទសម្លាប់មនុស្សដោយចេតនាគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណោចសាលក្រមលេខ ០៩ ចុះថ្ងៃទី ២៣-១២-១៩៩៦ របស់តុលាការខេត្តកំពត ។

២៥-ទណ្ឌិតឈ្មោះ **ផៃ រតនា** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៥-១៩៩៨ ពីបទសម្លាប់មនុស្សដោយចេតនានឹងអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណោចសាលក្រមលេខ ៤២ ចុះថ្ងៃទី ០១-១០-១៩៩៨ របស់តុលាការខេត្តកំពត ។

២៦-ទណ្ឌិតឈ្មោះ **ខែត សាយ** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៤-១៩៩៩ ពីបទប្លន់ទ្រព្យសម្បត្តិពលរដ្ឋ និងកាន់កាប់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណោចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ១៥-៩-១៩៩៩ របស់តុលាការខេត្តកំពត ។

២៧-ទណ្ឌិតឈ្មោះ **ស្វាយ យ៉ាន់** ភេទស្រី អាយុ ៥០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៩-២០០០ ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ១០-៥-២០០១ របស់តុលាការខេត្តកំពត ។

២៨-ទណ្ឌិតឈ្មោះ **អ៊ិន សុវណ្ណា** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៩-១៩៩៩ ពីបទចាប់ជំរិតមនុស្សទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥"ង" ចុះថ្ងៃទី ០១-៣-២០០៥ របស់សាលាឧទ្ធរណ៍ ។

២៩-ទណ្ឌិតឈ្មោះ **ជុន សំអុល** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៥-១៩៩៩ ពី បទលក់ដូរមនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣"ក" ចុះថ្ងៃទី ២០-៩-១៩៩៩ របស់តុលាការខេត្តកណ្តាល ។

៣០-ទណ្ឌិតឈ្មោះ **ជុះ សំអាត** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៩-១៩៩៨ ពី បទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦"ក" ចុះថ្ងៃទី ១៩-០២-១៩៩៩ របស់តុលាការខេត្តកណ្តាល ។

៣១-ទណ្ឌិតឈ្មោះ **ចាប ចូច** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-៨-១៩៩៦ ពី បទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២"ក" ចុះថ្ងៃទី ១៦-៩-១៩៩៦ របស់តុលាការខេត្តកណ្តាល ។

៣២-ទណ្ឌិតឈ្មោះ **សោម ទ្រី** ហៅ **សេង សុផល** ភេទ ប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១១-១៩៩៩ ពីបទប្លន់ចាប់ជំរិត និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១១-៤-២០០០ របស់តុលាការខេត្តក្រចេះ ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ៤៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **រ័ត្ន ស៊ីណា** ភេទប្រុស អាយុ ១៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-១២-១៩៩៦ ពីបទប្លន់ទ្រព្យសម្បត្តិ និងសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១០-០១-១៩៩៧ របស់តុលាការខេត្តស្វាយរៀង ។

២-ទណ្ឌិតឈ្មោះ **ស៊ុម សំអាត** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៧-១៩៩៩ ពីមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥ ចុះថ្ងៃទី ២៣-៩-១៩៩៩ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៣-ទណ្ឌិតឈ្មោះ **ចាន់ ថេត** ហៅ **នួន សុផា** ភេទប្រុស អាយុ ១៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-២០០២ ពីបទរួមគំនិតធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៤០ ចុះថ្ងៃទី ០៩-១២-២០០២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤-ទណ្ឌិតឈ្មោះ **សុខ ធឿន** ហៅ **គ្រោះធឿន** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១០-២០០១ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៥-០១-២០០២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៥-ទណ្ឌិតឈ្មោះ **ឈុំ ខន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៥-២០០៤ ពីបទប្លន់ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ៦ ខែ តាមអំណោចសាលក្រមលេខ ១៣៣ ចុះថ្ងៃទី ០៨-១១-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៦-ទណ្ឌិតឈ្មោះ **ហ៊ិន សំអុល** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៥-២០០១ ពីបទប្លន់ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ៦ ខែ តាមអំណោចសាលក្រមលេខ ១៣៣ ចុះថ្ងៃទី ០៨-១១-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៧-ទណ្ឌិតឈ្មោះ **កែវ វណ្ណា** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៩-២០០២ ពីចោរកម្មលួចគោញីមួយក្បាល ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៩ ចុះថ្ងៃទី ០៥-០២-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៨-ទណ្ឌិតឈ្មោះ **ហេង ឥន្ទី** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៦-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៣១ ចុះ ថ្ងៃទី ០៥-១២-២០០៣ របស់តុលាការក្រុងព្រះសីហនុ ។

៩-ទណ្ឌិតឈ្មោះ **កែ ដានិត** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-១២-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធដែលហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ៤២ ចុះថ្ងៃទី ០៣-៣-២០០៣ របស់តុលាការក្រុងព្រះសីហនុ ។

១០-ទណ្ឌិតឈ្មោះ **លី ម៉ាន់** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-១២-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណោចសាលក្រមលេខ ៧៨ ចុះថ្ងៃទី ២៧-៦-២០០៣ របស់តុលាការក្រុងព្រះសីហនុ ។

១១-ទណ្ឌិតឈ្មោះ **លឹម ទាសនា** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-៦-២០០៤ ពីបទចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណោចសាលក្រមលេខ ១០៤ ចុះថ្ងៃទី ០១-១២-២០០៤ របស់តុលាការក្រុងព្រះសីហនុ ។

១២-ទណ្ឌិតឈ្មោះ **ជា ដារ៉ា** ហៅ **ព្រា** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៦-២០០៤ ពីបទបង្ករបួសដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណោចសាលក្រមលេខ ៩៩ ចុះថ្ងៃទី ១៦-១១-២០០៤ របស់តុលាការក្រុងព្រះសីហនុ ។

១៣-ទណ្ឌិតឈ្មោះ **ឈាង គឹមឆាយ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៤-២០០៣ ពីបទបង្ករបួសដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២៨-០១-២០០៤ របស់តុលាការក្រុងព្រះសីហនុ ។

១៤-ទណ្ឌិតឈ្មោះ **នន ម៉ាក** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-១២-២០០២ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ២១ ចុះថ្ងៃទី ០៥-០២-២០០៣ របស់តុលាការខេត្តសៀមរាប ។

១៥-ទណ្ឌិតឈ្មោះ **លិត ជួក** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៩-២០០០ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៨-០១-២០០១ របស់តុលាការខេត្តសៀមរាប ។

១៦-ទណ្ឌិតឈ្មោះ **ចាន់ សុជា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-០១-២០០៤ ពីបទបង្ករបួសស្នាមដោយចេតនាបណ្តាលឱ្យស្លាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ៦១"ក" ចុះថ្ងៃទី ២៥-៣-២០០៤ របស់តុលាការខេត្តសៀមរាប ។

១៧-ទណ្ឌិតឈ្មោះ **នួច គ្រឹម** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១១-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រម លេខ ០២ ចុះថ្ងៃទី ០៨-០១-២០០១ របស់តុលាការខេត្តសៀមរាប ។

១៨-ទណ្ឌិតឈ្មោះ **ខាន់ ធុន្នី** ហៅ **ម៉ាំ វុទ្ធី** ភេទប្រុស អាយុ ១៩ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-៦-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណោចសាលក្រមលេខ ៦៤ ចុះថ្ងៃទី ១៨-៨-២០០៣ របស់តុលាការខេត្តក្រចេះ ។

១៩-ទណ្ឌិតឈ្មោះ **នាយ សេន** ភេទប្រុស អាយុ ២៥ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៨-២០០៣ ពីបទឆបោកទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២៤-៣-២០០៤ របស់តុលាការខេត្តក្រចេះ ។

២០-ទណ្ឌិតឈ្មោះ **សឿ ភូពិជេត** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៩-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និងប៉ុនប៉ងធ្វើមនុស្សឃាដ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស

ដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ២៦"ក" ចុះថ្ងៃទី ០១-៣-២០០១ របស់តុលាការខេត្តកំពង់ចាម ។

២១-ទណ្ឌិតឈ្មោះ **អោម ឃឹម** ភេទប្រុស អាយុ ៣៧ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-០២-២០០០ ពីបទធ្វើមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ១០៩"ក" ចុះថ្ងៃទី ០៤-៧-២០០០ របស់តុលាការខេត្តកំពង់ចាម ។

២២-ទណ្ឌិតឈ្មោះ **ហេង ឡាលីន** ភេទប្រុស អាយុ ២៨ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៩-២០០១ ពីបទចាប់មនុស្សជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ១១"ជ" ចុះថ្ងៃទី ១៣-៣-២០០២ របស់តុលាការក្រុងភ្នំពេញ ។

២៣-ទណ្ឌិតឈ្មោះ **ម៉ែន សារិន** ភេទប្រុស អាយុ ២៧ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៧-២០០២ ពីបទមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលដីកាលេខ ៧៦"ង" ចុះថ្ងៃទី ១២-៨-២០០៤ របស់សាលាឧទ្ធរណ៍ ។

២៤-ទណ្ឌិតឈ្មោះ **លន់ រតនៈ** ភេទប្រុស អាយុ ១៩ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៣-២០០០ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណោចសាលដីកាលេខ ០៤"ឈ" ចុះថ្ងៃទី ២២-០១-២០០៣ របស់សាលាឧទ្ធរណ៍ ។

២៥-ទណ្ឌិតឈ្មោះ **គឹម សុផល** ភេទប្រុស អាយុ ២២ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៤-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលដីកាលេខ ៣៩"ក" ចុះថ្ងៃទី ២២-៧-២០០៤ របស់សាលាឧទ្ធរណ៍ ។

២៦-ទណ្ឌិតឈ្មោះ **សេខ ហួត** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៣-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ៩៩ ចុះថ្ងៃទី ២៩-១០-២០០៣ របស់តុលាការខេត្តកំពត ។

២៧-ទណ្ឌិតឈ្មោះ **សាម ណែត** ភេទស្រី អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៣-២០០៤ ពីបទសម្លាប់មនុស្សដោយអចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណោចសាលក្រមលេខ ១២ ចុះថ្ងៃទី ១៧-០១-២០០៥ របស់តុលាការខេត្តកំពត ។

២៨-ទណ្ឌិតឈ្មោះ **ម៉ិ សារ៉ុម** ភេទប្រុស អាយុ ២៥ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៣-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណោចសាលក្រម លេខ ៨៣"ឆ" ចុះថ្ងៃទី ១៥-១១-២០០១ របស់តុលាការក្រុងភ្នំពេញ ។

២៩-ទណ្ឌិតឈ្មោះ **សេក ច្រាខ** ភេទប្រុស អាយុ ១៨ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៥-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណោចសាលក្រមលេខ ០៣"ឈ" ចុះថ្ងៃទី ០៨-០១-២០០៣ របស់តុលាការក្រុងភ្នំពេញ ។

៣០-ទណ្ឌិតឈ្មោះ **អ៊ុច រដ្ឋា** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៥-២០០១ ពីបទប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណោចសាលក្រមលេខ ២៧"ង" ចុះថ្ងៃទី ១០-៤-២០០២ របស់តុលាការក្រុងភ្នំពេញ ។

៣១-ទណ្ឌិតឈ្មោះ **សាំខ ទុន** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-០២-២០០១ ពីបទមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណោចសាលក្រមលេខ ៤៦"ខ" ចុះថ្ងៃទី ២៤-៧-២០០១ របស់តុលាការក្រុងភ្នំពេញ ។

៣២-ទណ្ឌិតឈ្មោះ **ម៉ុល ជុក** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៥-១៩៩៨ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៣"ក" ចុះ ថ្ងៃទី ២០-៧-១៩៩៨ របស់តុលាការខេត្តកណ្តាល ។

៣៣-ទណ្ឌិតឈ្មោះ **ហួត យួន** ភេទប្រុស អាយុ ៦៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-០២-២០០០ ពីបទមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណោចសាលក្រមលេខ ២៨"ក" ចុះថ្ងៃទី ០៣-៥-២០០០ របស់តុលាការខេត្តកណ្តាល ។

៣៤-ទណ្ឌិតឈ្មោះ **ម៉ុន រិន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-១០-១៩៩៩ ពីបទមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណោចសាលក្រមលេខ ១៩"ក" ចុះថ្ងៃទី ២៨-៣-២០០០ របស់តុលាការខេត្តកណ្តាល ។

៣៥-ទណ្ឌិតឈ្មោះ **សាយ សុខ** ភេទប្រុស អាយុ ២៤ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១២-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណោចសាលក្រមលេខ ៤៣"ក" ចុះ ថ្ងៃទី ១៩-៨-២០០៣ របស់តុលាការខេត្តកណ្តាល ។

៣៦-ទណ្ឌិតឈ្មោះ **ហាម ហ៊ាន** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៨-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណោចសាលក្រមលេខ ៤៣"ក" ចុះថ្ងៃទី ១៩-៨-២០០៣ របស់តុលាការខេត្តកណ្តាល ។

៣៧-ទណ្ឌិតឈ្មោះ **អឿ អុល** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១២-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណោចសាលក្រមលេខ ៤៣"ក" ចុះថ្ងៃទី ១៩-៨-២០០៣ របស់តុលាការខេត្តកណ្តាល ។

៣៨-ទណ្ឌិតឈ្មោះ **គួន ម៉េង** ភេទប្រុស អាយុ ៥៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០១-២០០៣ បទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រម លេខ ២៣"ព" ចុះថ្ងៃទី ២៤-៤-២០០៣ របស់តុលាការខេត្តកណ្តាល ។

៣៩-ទណ្ឌិតឈ្មោះ **ទ៉េន ឧត្តម** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៣-២០០៣ ពីបទបង្គ្រោះថ្នាក់ចរាចរ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤"រ" ចុះថ្ងៃទី ០៦-៦-២០០៣ របស់តុលាការខេត្តកណ្តាល ។

៤០-ទណ្ឌិតឈ្មោះ **កែវ ស៊ីថា** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-៤-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥"ក" ចុះថ្ងៃទី ១៦-៩-២០០៣ របស់តុលាការខេត្តកណ្តាល ។

៤១-ទណ្ឌិតឈ្មោះ **ឌឹម សុខេន** ភេទស្រី អាយុ ៣៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-០១-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១"គ" ចុះថ្ងៃទី ០៥-៦-២០០៣ របស់តុលាការខេត្តកណ្តាល ។

